**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**តុលាការក្រុងព្រះសីហនុ**
<u>សំណុំរឿងព្រហ្មទណ្ឌ</u>
លេខ ២០ ចុះថ្ងៃទី ២៦
ខែ មករា ឆ្នាំ ២០០៤
<u>សាលក្រម</u>
លេខ ១១៥ ចុះថ្ងៃទី ១៦
ខែ ធ្នូ ឆ្នាំ ២០០៤

*សាលក្រមនេះបានចូលជាស្ថាពរហើយ ។*
*ក្រុងព្រះសីហនុ ថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០០៥*
**ក្រឡាបញ្ជី**
[redacted]

## តាមនាមប្រជារាស្ត្រខ្មែរ
## តុលាការក្រុងព្រះសីហនុ

បង្កើតឡើងតាមច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តី ដែលប្រកាសអោយប្រើតាមក្រឹត្យលេខ ០៦ ក្រ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៣ បានបើកសវនាការជាសាធារណៈនៅតុលាការក្រុងព្រះសីហនុ នាថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០០៤ ដោយមានសមាសភាពដូចតទៅនេះ :

**<u>ចៅក្រមជំនុំជំរះ</u>**

លោក [redacted] អនុប្រធានតុលាការក្រុងព្រះសីហនុ

**<u>តំណាងអយ្យការ</u>**

លោក [redacted] ព្រះរាជអាជ្ញាស្តីទីអមតុលាការក្រុងព្រះសីហនុ

**<u>ក្រឡាបញ្ជីសវនាការ</u>**

លោក [redacted] ក្រឡាបញ្ជីតុលាការក្រុងព្រះសីហនុ

ដើម្បីជំនុំជំរះលើសំណុំរឿងព្រហ្មទណ្ឌលេខ ២០ ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០០៤ ដែលមានជនជាប់ចោទឈ្មោះ ដូចខាងក្រោមនេះ :

១-ឈ្មោះ **ឃ ម** ឈ្មោះហៅក្រៅ **រ** ភេទប្រុស អាយុ ១៩ឆ្នាំ ជាតិខ្មែរ កើតនៅភូមិច្រកជីតាំ ឃុំកំពែង ស្រុកគីរីវង្ស ខេត្តតាកែវ ទីលំនៅសព្វថ្ងៃក្រុម ២២ ភូមិបឹងវែង សង្កាត់វាលរេញ ខណ្ឌព្រៃនប់ ក្រុងព្រះសីហនុ របររកស៊ី កូនសិស្សថ្នាក់ទី១២ ឪពុកឈ្មោះ **ឃ គ** (រ) ម្តាយឈ្មោះ **ថ ឧ** (រ) ប្រពន្ធកូនគ្មាន ទោសពីមុន *គ្មាន* សព្វថ្ងៃនៅក្រៅឃុំ ។

២-ឈ្មោះ **ង សខ** ឈ្មោះហៅក្រៅ **ស ឧ** ភេទប្រុស អាយុ ១៧ឆ្នាំ ជាតិខ្មែរ កើតនៅភូមិបឹងវែង សង្កាត់វាលរេញ ខណ្ឌព្រៃនប់ ក្រុងព្រះសីហនុ របររកស៊ីកូនសិស្សថ្នាក់ទី ១០ ឪពុកឈ្មោះ **ង ង** (ស) ម្តាយឈ្មោះ **ភ ថ ឈ** (រ) ប្រពន្ធកូនគ្មាន ទោសពីមុន *គ្មាន* សព្វថ្ងៃនៅក្រៅឃុំ ។

-ត្រូវជាប់ចោទពីបទ<u>បង្ករបួសដោយចេតនា</u> ប្រព្រឹត្តនៅភូមិបឹងវែងសង្កាត់វាលរេញ ខណ្ឌព្រៃនប់ ក្រុងព្រះសីហនុ កាលពីថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ២០០៣ បទល្មើសព្រហ្មទណ្ឌដែលមានចែង និង អោយផ្តន្ទាទោស តាមមាត្រា ៤១ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

-ឈ្មោះ **ច គ** ភេទប្រុស អាយុ ២៧ឆ្នាំ ជាតិខ្មែរ របររកស៊ីកម្មករ មានទីលំនៅសព្វថ្ងៃក្រុម២២ ភូមិបឹងវែង សង្កាត់វាលរេញ ខណ្ឌព្រៃនប់ ក្រុងព្រះសីហនុជាជនរងគ្រោះ ។

-ឈ្មោះ **ច គ** ភេទប្រុស អាយុ ៥០ឆ្នាំ ជាតិខ្មែរ របររកស៊ីធ្វើស្រែ មានទីលំនៅសព្វថ្ងៃក្រុម ៥ ភូមិដាស់ស្គ ឃុំបឹងសាឡាងខាងជើង ស្រុកកំពង់ត្រាច ខេត្តកំពត ជា

ដើមបណ្តឹងអោយឈ្មោះ ច គ ។

-ឈ្មោះ ម ល ភេទប្រុស អាយុ ២១ឆ្នាំ ជាតិខ្មែរ របររកស៊ី កូនសិស្សព្រះគុម្ពីរ មានទីលំនៅសព្វថ្ងៃ ក្រុម ២២ ភូមិបឹងវែង សង្កាត់វាលរេញ ខណ្ឌព្រៃនប់ ក្រុងព្រះសីហនុ ជាជនរងគ្រោះ និង ជាដើមបណ្តឹង ។

-បានឃើញដីកាសន្និដ្ឋានស្ថាពរលេខ ៨៤៥ ដស៣.០៤ ចុះថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ២០០៤ របស់តំណាងអយ្យការអមតុលាការក្រុងព្រះសីហនុ ។

-បានឃើញដីកាបញ្ជូនរឿងទៅជំនុំជំរះលេខ ១២៧២ ត.៣.០៤ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០៤ របស់ចៅក្រមស៊ើបអង្កេតនៃតុលាការក្រុងព្រះសីហនុ ។

-បានដីកាចាត់តាំងចៅក្រមជំនុំជំរះលេខ ១២៧៨ ត៣.០៤ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០៤ របស់ប្រធានតុលាការក្រុងព្រះសីហនុ ។

## ការប្រព្រឹត្តរបស់ជនជាប់ចោទមានដូចតទៅ :

-កាលពីថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៣ វេលាម៉ោង ១៩ នៅខាងក្រោយផ្សារវាលរេញ មានការឈ្លោះគ្នា ដែលបង្កដោយមនុស្សមួយក្រុមមានគ្នា ០៤នាក់ គឺឈ្មោះ ឃ ចរ, ហ សន, ទ ថ និងឈ្មោះ ជ បានប្រើប្រាស់កាំបិត ពូថៅ និង ដែកបំពង់ទីប ធ្វើជាអាវុធវាយទៅលើឈ្មោះ ឈ ម និង ច គ បណ្តាលអោយមានរបួសបែកក្បាលទាំង ០២នាក់ ទៅសំរាកព្យាបាលនៅគ្លីនិកឯកជន ឯឈ្មោះជនល្មើស ០២នាក់ទៀត ឈ្មោះ ទ ថ និងឈ្មោះ ជ គ្មានប្រវត្តិរូបច្បាស់លាស់ ក្រោយពេលប្រព្រឹត្តបទល្មើសរួចឈ្មោះទាំង ០២នាក់នេះ រត់គេចខ្លួនបាត់ដល់សព្វថ្ងៃ ។

## នារពេលសវនាការ

ឈ្មោះ ឃ ចរ ជាជនជាប់ចោទបានឆ្លើយថា កាលពីថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ២០០៣ វេលាម៉ោង ០៧ កន្លះយប់ ខ្លួន និង ហ ស ន (ហ រ ន) បាននាំគ្នាទៅមើលវីដេអូនៅហាងកាហ្វេអ៊ីហាយ ពេលនោះខ្លួនក៏ឃើញ ឈ្មោះ ឆ, ឈ្មោះ ន កំពុងតែតប់គ្នាជាមួយឈ្មោះ ញ ។ ដោយឃើញដូច្នេះ ខ្លួន និង ហ ស ន ក៏ចូលទៅចាប់ឃាត់ ស្រាប់តែឈ្មោះ ណ ដែលត្រូវជាឪពុករបស់ឈ្មោះ ឆ និង ឈ្មោះ ន បានយកពិលមកវាយចំក្បាល ខ្លួនត្រូវចំត្រចៀកខាងស្តាំមួយពិល ។ ពេលនោះខ្លួន និង ឈ្មោះ ហ ស ន ព្រមទាំងឈ្មោះ ញ ក៏នាំគ្នាទៅផ្ទះ ឈ្មោះ ឈ ពេលទៅដល់ក៏ឃើញក្រុមរបស់ ច គ មានគ្នាប្រហែល ១០នាក់ គឺស្គាល់តែ ច គ និង ឈ្មោះ ឃ ឃើញ ច គ កាន់ឈើ ៥ x ៥ បួនជ្រុងប្រហែលកន្លះម៉ែត្រ ០១ដើម ឈ្មោះ ឃ កាន់ខ្សែក្រវ៉ាត់ ពេលក្រុមនេះមកដល់ ក៏ឃើញវារិសដុំថ្មគប់សំដៅផ្ទះ ឈ ដែលក្រុមគ្រួសារគេកំពុងតែហូបបាយ ស្រាប់តែឃើញ ម ល ក៏ចេញមកសួរ ក៏ត្រូវឈ្មោះ ច គ យកឈើ ៥ x ៥ បួនជ្រុងមកវាយ ម ល តែ ម ល គេចដែរតែគេចមិនផុត ក៏ត្រូវចុងដំបងឈើត្រូវក្បាលខាងឆ្វេង ឃើញមានរលាត់ស្បែកមានឈាមហូរ ឈ្មោះ ច គ ក៏ស្រែកអោយឈ្មោះ ជ ថាអាឯងចង់លេងជាមួយអញឬ? ឈ្មោះ ឃ ក៏យកខ្សែក្រវ៉ាត់វាយទៅលើឈ្មោះ ម ល ទៀតត្រូវជើងស្រេ ពេលនោះឪពុករបស់ខ្លួនបានហៅខ្លួនអោយត្រលប់មកផ្ទះវិញ ហើយរឿងអ្វីតទៅទៀតខ្លួនមិនបានដឹងឡើយ ។

-ឈ្មោះ ហ ស ន ជាជនជាប់ចោទបានឆ្លើយថា នៅថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ២០០៣ វេលាម៉ោង ០៧យប់ ខ្លួន និងឈ្មោះ ឃ ចរ បាននាំគ្នាទៅហូបកាហ្វេ និង មើលវីដេអូនៅហាងអ៊ីហាយ ពេលនោះក៏ឃើញឈ្មោះ ឆ, ឈ្មោះ ន កំពុងតែវាយតបគ្នាជាមួយឈ្មោះ ស ប ញ ដែលជាមិត្តភក្តិរៀនជាមួយខ្លួន ក៏បានចូលទៅឃាត់កុំអោយគេវាយតប់គ្នា ភ្លាមនោះដែរ ខ្លួនក៏ឃើញឈ្មោះ ណ ជាឪពុករបស់ឈ្មោះ ឆ និង ឈ្មោះ ន យកពិលមក

វាយក្បាល ឃ បះ ចំនួន ០១ពិល ក្នុងពេលនេះក៏ឃើញបងប្អូនរបស់ឈ្មោះ ឆ និង ន តែខ្លួនមិនស្គាល់ឈ្មោះបាន នាំគ្នាលើកកៅអីជ័រវាយទៅលើឈ្មោះ ស ម ញ តែមិនបណ្តាលអោយរបួសឡើយ ខ្លួនក៏ចាប់ដៃទាញ ស ម ញ រត់សំដៅទៅផ្ទះវា មិនទាន់ទៅដល់ផង ទើបតែដល់ផ្ទះ ម ល ស្រាប់តែឃើញក្រុមរបស់ឈ្មោះ គ ម្នាក់ៗមានកាន់កាំបិត ពូថៅ និង ដំបង ឃើញឈ្មោះ គ កាន់ឈើ ៥ x ៥ បូនជ្រុង ដោយឃើញដូច្នេះខ្លួន និង ឃ បះ ព្រមទាំងឈ្មោះ ញា ក៏នាំគ្នារត់ចូលផ្ទះ ម ល ដែលគេកំពុងតែហូបបាយពេលល្ងាច ក៏ឃើញក្រុមរបស់ គ រើសដុំថ្មគប់ចូលផ្ទះ ម ល ឈ្មោះ ល ក៏ចេញមកសួរ តែឈ្មោះ គ ថាអាជាអាឯងចង់លេងជាមួយអញ ឈ្មោះ គ ក៏លើកដំបងវាយទៅលើឈ្មោះ ល តែ ល គេចដែរ ក៏ត្រូវចុងឈើត្រូវក្បាលមានឈាមហូរ ដោយឃើញមានឈាមហូរក្រុមរបស់ គ ក៏នាំគ្នាចេញទៅបាត់ទៅ ក៏ឃើញឪពុក ឃ បះ នាំ ម រ ទៅផ្ទះ ខ្លួន និង ញ ក៏នាំគ្នាទៅផ្ទះដែរ ។ ខ្លួនសុំបញ្ជាក់ថា ចំពោះក្បាលរបស់ឈ្មោះ ច គ ដែលបែកនោះ គឺខ្លួនមិនបានដឹងឡើយគ្រាន់តែដឹងថា កន្លងមកឈ្មោះ គ ធ្លាប់មានទំនាស់ជាមួយឈ្មោះ ៩ ។

-តាមការអានចម្លើយរបស់ឈ្មោះ ច.គ ជាជនរងគ្រោះបានឆ្លើយថា មុនកើតហេតុមួយថ្ងៃឈ្មោះ ឆ ជាប្អូនជីដូនមួយរបស់ខ្លួនបានបុកបីយ៉ែរនៅផ្ទះឈ្មោះ ឃ បះ ក៏មានការឈ្លោះប្រកែកគ្នាជាមួយឈ្មោះ ឃ បះ រឿងហេតុនេះក៏ចប់សព្វគ្រប់ទៅ ។ នៅថ្ងៃកើតហេតុនោះដែរ វេលាម៉ោង ០៧ ខ្លួននៅផ្ទះកំពុងតែដេក ស្រាប់តែម្តាយមីងខ្លួនឈ្មោះ រី រត់ទៅដល់ផ្ទះខ្លួន ហើយនិយាយប្រាប់ថា ពេលគាត់កំពុងតែអង្គុយមើលទូរទស្សន៍នៅហាងអ៊ីហាយក៏កូនគាត់ឈ្មោះ ស ន ក៏ទៅមើលដែរ ។ ស្រាប់ពេលនោះឈ្មោះ ឃ បះ ក៏ទៅដែរ ហើយហៅ ន អោយចេញមកក្រៅ ក៏ចាប់ឈ្មោះ ន វាយតែម្តង ម្តាយមីងខ្លួនក៏ចេញមកសួរនាំ ក៏ត្រូវឈ្មោះ ឃ បះ វាយ ១ ដៃកចំក្បាលបណ្តាលអោយបែកហូរឈាមត្រូវពេទ្យដេរអស់ចំនួន ០៥ថ្នេរ ឮដំណឹងយ៉ាងដូច្នេះ ខ្លួនក៏រត់ទៅមើលដល់កន្លែងកើតហេតុនៅមុខហាងកាហ្វេអ៊ីហាយ ពេលទៅដល់ឃើញឈ្មោះ ឃ បះ កំពុងតែវាយ ន ដោយដៃរបស់វា ហើយគ្នាវាចំនួន០៥នាក់ទៀត តែខ្លួនមិនហ៊ានចូលទៅឃាត់ឡើយ ក៏ឃើញឈ្មោះ ន ខិតខំបំរះរត់រួចខ្លួនទៅផ្ទះបងប្អូនវា អោយជួយក៏ឃើញឈ្មោះ ឃ បះ នាំគ្នាទៅកន្លែងការ៉ាអូខេវិញ ស្រាប់តែឈ្មោះ ន បាននាំបងប្អូនរបស់វាទៅរក ឈ្មោះ ឃ បះ ឃើញដូច្នេះខ្លួនក៏ទៅឃាត់ក្រុមគ្រួសាររបស់ឈ្មោះ ន កុំអោយទៅរករឿងគេ ស្រាប់តែឈ្មោះ ឃ បះ បានកាន់កាំបិតប៉ុងតោគប់ចេញពីក្រោមផ្ទះហាងការ៉ាអូខេមក ត្រូវចំហៀងក្បាលខាងឆ្វេងរបស់ខ្លួនបណ្តាលឱ្យខ្លួន សន្លប់ដេកពេទ្យដេរអស់ ០៩ថ្នេរ ។ ចំពោះបញ្ហានេះ ខ្លួនទុកសិទ្ធិអោយឪពុករបស់ខ្លួនជាអ្នកទារសំណងថ្លៃថ្នាំព្យាបាលរបួស ។

-តាមការអានចម្លើយរបស់ឈ្មោះ ច ត ជាដើមបណ្តឹងបានឆ្លើយថា នៅថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ២០០៣ វេលាម៉ោង ០៦ព្រឹក ខ្លួនបានទទួលទូរស័ព្ទប្រាប់ថា កូនប្រុសឈ្មោះ ច គ ត្រូវឈ្មោះ ឃ បះ បានកាប់វាចំក្បាលបណ្តាលអោយមានរបួស ហើយសន្លប់ និង ត្រូវបានគេដឹកទៅដល់មន្ទីរពេទ្យ ឮដូច្នេះខ្លួនក៏ធ្វើដំណើរមកមើលនៅវាលរេញក៏ឃើញសំរាកនៅផ្ទះពេទ្យវាលរេញ ឃើញរបួសវាពេទ្យដេរអស់ ០៩ថ្នេរ ។ ក្នុងរឿងនេះខ្លួនទាមទារសំណងថ្លៃថ្នាំព្យាបាលរបួសជាទឹកប្រាក់ចំនួន ១.៥០០.០០០៛០០ បើឈ្មោះនេះបានបង់ប្រាក់សុំអោយតុលាការលើកលែងទោស តែបើមិនព្រមបង់ប្រាក់ទេ សុំអោយតុលាការធ្វើតាមច្បាប់ទៅចុះ ។

-ឈ្មោះ ម ល ជាដើមបណ្តឹងបានឆ្លើយថា នៅថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ២០០៣ វេលាម៉ោង ០៧យប់ក្រុមគ្រួសារខ្លួនរៀបចំហូបបាយនៅផ្ទះ ក៏ឃើញៈឈ្មោះ ឃ បះ, ឈ្មោះ ជា, ឈ្មោះ ស ន និងឈ្មោះ ទ ដែលអ្នករស់នៅក្នុងភូមិជាមួយខ្លួនដែរ ក៏បាននាំគ្នាចូលផ្ទះខ្លួន ហើយឈ្មោះ ឃ បះ បានប្រាប់ខ្លួនថា "អា ល គេវាយអញហើយ" ភ្លាមនោះស្រាប់តែមានមនុស្ស ០១ក្រុមប្រហែល ១០នាក់ ឈរនៅខាងក្រៅរបងផ្ទះ ជ្រុងខាងលិចឈៀងខាងត្បូងបានគប់ដុំថ្មចូលផ្ទះខ្លួន ។ ឃើញសភាពដូច្នេះ ខ្លួនក៏ចេញទៅក្រៅរបងផ្ទះ ដើម្បីសួរនាំរឿងហេតុនេះ ពេលនោះឈ្មោះ គ បានស្រែកអោយខ្លួនថា "អា ៩ ហ្អែងចង់លេងជាមួយអញឬ" តាមពិតខ្លួនមិនមែនឈ្មោះ ៩ នោះទេ ឈ្មោះ គ

នេះវាប្រឡំខ្លួនទៅឈ្មោះ **ឌ** វិញ ព្រោះកន្លងមកឈ្មោះ **ឌ** និង **គ** បានឈ្លោះគ្នារួចទៅហើយ ។ ក្នុងពេលនោះដែរ ឈ្មោះ **ឃ** ដែលនៅក្នុងក្រុមជាមួយគ្នានេះ បានយកខ្សែក្រវ៉ាត់របស់វា វាយមកលើខ្លួនតែត្រូវខ្លួនគេចផុត ក៏ឃើញ **គ** បានយកឈើ ៥ x ៥ ប្រវែង ៧០ ស.ម មកវាយខ្លួនទៀត ខ្លួនគេចដែរ តែត្រូវ ចំចុងឈើ ៥ x ៥ នោះ ត្រង់សៀតថ្ងាបណ្តាលអោយខ្លួនរលាត់ស្បែក និង មានឈាមនៅមុខខ្លួន ពេលនោះខ្លួនក៏ខឹងពួកវាយ៉ាងខ្លាំង ខ្លួនក៏សំរុកចូលទៅលើវា វាក៏ដកថយទៅឈរនៅព្រំដីម្តងទៀត ហើយពោលពាក្យថា វាទៅយកកាំភ្លើងមកបាញ់ពួកហ្អែងទៀត ពួកវាក៏ដើរចេញបាត់អស់ទៅ ខ្លួនក៏ចូលផ្ទះបានពេទ្យជូតឈាម និង ដាក់ថ្នាំព្យាបាលអោយ និង ទារសំណងព្យាបាលរបួស និង ជំងឺចិត្តជាទឹកប្រាក់ចំនួន ១.000.000រុ00 ( មួយលានរៀល ) បើឈ្មោះនេះសងទើបអោយរួចខ្លួន បើមិនសងទេសុំអោយផ្តន្ទាទោសតាមច្បាប់ ចំពោះឈ្មោះ **ឃ មរ** និង **ម ស ន** មិនបានប្រព្រឹត្តអ្វីខុសឆ្គងនោះឡើយ ការឆ្លើយរបស់ **ច គ** គឺមិនត្រឹមត្រូវឡើយ ។

-ឈ្មោះ **ស ណ** ជាសាក្សី បានឆ្លើយថា នៅថ្ងៃកើតហេតុវេលាម៉ោង 0៧យប់ ខ្លួនកំពុងតែហូបកាហ្វេនៅហាងអ៊ីហាយ ក៏បានឃើញ **ឃ មរ**, ឈ្មោះ **ឌា** និងឈ្មោះ **ថ** បានទៅដល់ហាងកាហ្វេ ហើយពេលនោះខ្លួនក៏ឃើញឈ្មោះ **ឌ** ដើរចូលទៅក្នុងហាងកាហ្វេ ហើយបានទាញដៃឈ្មោះ **ន** ចេញមកក្រៅហាង ហើយឈ្មោះ **ឌ** បានវាយទៅលើឈ្មោះ **ន** ដោយដៃ ជាច្រើនដៃ មិនបណ្តាលអោយមានរបួសឡើយ ។ ក្នុងពេលនោះដែរ ខ្លួនឃើញម្តាយឈ្មោះ **ន** ដែលនៅក្បែរនោះបំរុងរត់ទៅជួយកូន ក៏ត្រូវបាន **ឃ មរ** យកដែកប៊ុនមេជើងប្រវែង ៣០ស.ម មកវាយចំក្បាលម្តាយឈ្មោះ **ន** បណ្តាលអោយបែកហូរឈាម ឈ្មោះ **ឃ មរ** ក៏រត់ទៅហាងការ៉ាអូខេ ក៏ឃើញឈ្មោះ **ច គ** រត់សំដៅទៅក្រុម **ឃ មរ** ក៏ត្រូវបក្ខពួក **ឃ មរ** យកកាំបិតប៊ុងតោគប់សំដៅមកលើឈ្មោះ **ច គ** បណ្តាលអោយមានរងរបួសក្បាលឈ្មោះ **ច គ** ក៏ដើរទៅពេទ្យដេរជាច្រើនថ្នេរ រឿងរ៉ាវអ្វីផ្សេងទៀត ខ្លួនពុំបានដឹងឡើយ ។

-ឈ្មោះ **ខ សថ** ជាសាក្សីបានឆ្លើយថា នៅព្រឹកថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២00៣ វេលាម៉ោង ៨:៣0នាទី ឈ្មោះ **ច ត** ជាឪពុកជនរងគ្រោះឈ្មោះ **ច គ** បានមកប្តឹងថា កូនគាត់ត្រូវឈ្មោះ **ឃ មរ** យកកាំបិតគប់ត្រូវក្បាលកំពុងតែព្យាបាលរបួសនៅផ្ទះពេទ្យ ហើយសុំអោយសមត្ថកិច្ចចាត់ការតាមនីតិវិធី បន្ទាប់មកសមត្ថកិច្ចនគរបាលយើងក៏បានដំណើរការស៊ើបសួរឃើញអ្នកបង្ករបួស គឺឈ្មោះ **ឌា** និងឈ្មោះ **វ ថ** ហើយបានគេចខ្លួនបាត់ទៀត តែក្រុម **ឃ មរ** ជាអ្នកជួយឃាត់តែប៉ុណ្ណោះ ។

-ឈ្មោះ **ឃ វ ស** ជាសាក្សីបានឆ្លើយថា នៅថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ២00៣ វេលាម៉ោង 0៧យប់ ខ្លួនបានព្យាបាលរបួសឈ្មោះ **ច គ** គឺត្រូវចំក្បាលបែកឈាមប្រឡាក់ពេញខ្លួន ខ្លួនក៏បានជូតឈាម និង កោរសក់ក៏ពិនិត្យមើលទំហំឃើញថា មុខរបួសទំហំមាន ៦.២ស.ម និង ជំរៅរហូតដល់លលាដ៍ក្បាល ប៉ែកខាងស្តាំក្បាល និង ថ្ងាសខាងមុខមានពកប៊ុនមេដៃ បានដេរចំនួន 0៦ថ្នេរ ជនរងគ្រោះសំរាកព្យាបាលរយៈពេល 0៤ថ្ងៃ ។

-ឈ្មោះ **អ ឆ** ជាសាក្សីបានឆ្លើយថា នៅល្ងាចថ្ងៃទី ២៩ ខែ មករា ឆ្នាំ ២00៣ វេលាម៉ោង 0៧យប់ ក្រុមគ្រួសារខ្លួនកំពុងតែហូបបាយ ក៏ឮសូរសំឡេងឈ្លោះប្រកែកគ្នា ក៏ខ្លួនដាក់ចានបាយចុះក៏រត់ទៅមើលក៏ឃើញឈ្មោះ **ញ** ហៅឈ្មោះ **ន** ចេញពីក្នុងហាងមកក្រៅហាងកាហ្វេយាយហាយ ឈ្មោះ **ន** ក៏ចេញមកដល់មាត់ទ្វារហាង ឈ្មោះ **ញ** ក៏ស្ទុះវាយឈ្មោះ **ន** ឯឈ្មោះ **ន** ក៏វាយឈ្មោះ **ញ** វិញដែរ ក៏មានការវាយតប់គ្នារវាង **ញ** និង **ន** ។ ឃើញដូច្នេះក៏ឃើញឈ្មោះ **ឃ មរ** ចូលទៅឃាត់ស្រាប់តែពេលនោះឪពុករបស់ឈ្មោះ **នួន** យកពិលវាយក្បាល **ម រ** ទៅវិញពួកនេះក៏ឈប់វាយគ្នាទៅ ។ ក្រុម **ម រ** មានឈ្មោះ **ឌ**, ឈ្មោះ **ស ន** និងឈ្មោះ **ញ** ឃើញដើរទៅផ្ទះឈ្មោះ **ឈ** ខ្លួនក៏ដើរតាមមើលមួយសន្ទុះ ក៏ឃើញក្រុមឈ្មោះ **ន** មានឈ្មោះ **ច គ**, ឈ្មោះ **ឌ** និង បក្ខពួកវាដើរសំដៅទៅផ្ទះ **ឈ** ដែរ ក្រុមនេះក៏នាំគ្នារើសដុំថ្មគប់សំដៅមកលើផ្ទះ **ឈ** ឈ្មោះ **ឈ** ក៏ចេញមកក្រៅ ស្រាប់តែឈ្មោះ **ច គ** ថាអោយ **ឈ** ថា

" នោះ ៥ ហ៊ែងចង់លេងជាមួយអញ" ក៏ឈ្មោះ ឃ ដោះខ្សែក្រវ៉ាត់វាយទៅលើ ឈ ត្រូវចំក្បាលចេញឈាមឈ្មោះ ឈ ក៏វាយទៅលើឈ្មោះ គ វិញ ហើយក៏មានការវាយប្រតប់គ្នា ដោយយប់ងងឹតពេកខ្លួនមិនអាចមើលឃើញមិនដឹងជាអ្នកណាត្រូវរបួសដូចម្តេចឡើយ ។

ក្រោយពេលកើតហេតុរួចហើយរហូតដល់សព្វថ្ងៃនេះ ឈ្មោះ គ, ឈ្មោះ ន, ឈ្មោះ ឆ, ឈ្មោះ ខ ៩ បានគេចខ្លួនមិនដឹងទៅរស់នៅទីណា ឯរឿងរ៉ាវអ្វីផ្សេងទៀត ខ្លួនពុំបានដឹងឡើយ ។

-បានឃើញលិខិតរបស់គ្រូពេទ្យព្យាបាល ចុះថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ២០០៣ បញ្ជាក់លើឈ្មោះ ច គ ភេទប្រុស អាយុ ២៥ឆ្នាំ បានចូលទៅពិនិត្យនៅថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ២០០៣ វេលាម៉ោង ១៩ :

១-បែកក្បាលផ្នែកខាងលើ ៦,២ស.ម ជំរៅរហូតដល់លលាដ៍

២-ពកថ្ងាសប៉ុនមេដៃ

-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា មានពិរុទ្ធភាពធ្ងន់ធ្ងរលើឈ្មោះ **ឃ មរ** និង ឈ្មោះ **ហ សន** ពីបទបង្ករបួសស្នាមដោយចេតនា ប្រព្រឹត្តនៅភូមិរ៉ែងវ៉ែង សង្កាត់វាលរេញ ខណ្ឌព្រៃនប់ ក្រុងព្រះសីហនុ កាលពីថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ២០០៣ ។

បទល្មើសព្រហ្មទណ្ឌមានចែងផ្តន្ទាទោសតាមមាត្រា ៤១ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។ ហេតុនេះសូមឱ្យលោកចៅក្រមជំនុំជំរះទៅតាមច្បាប់ ។

-ឈ្មោះ **ឃ មរ** បានឆ្លើយថា ខ្លួនមិនបានវាយឈ្មោះ **ច គ** នោះទេ គឺខ្លួនជាអ្នកជួយឃាត់ តែត្រូវឪពុករបស់ឈ្មោះ **ន** វាយត្រូវមួយពិលចំក្បាលថែមទៀត ហើយខ្លួនអិនបានប្រព្រឹត្តដូចតំណាងអយ្យការចោទប្រកាន់នោះទេ ។

-ឈ្មោះ **ហ សន** បានឆ្លើយថា ខ្លួនក៏មិនបានប្រព្រឹត្តដូចតំណាងអយ្យការចោទប្រកាន់នោះទេ ។

-ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ

-ក្រោយពីបានស្តាប់ការអានចម្លើយជនរងគ្រោះ

-ក្រោយពីបានស្តាប់ការអានចម្លើយរបស់ដើមបណ្តឹង

-ក្រោយពីបានស្តាប់ចម្លើយសាក្សី

-ក្រោយពីបានពិនិត្យភស្តុតាង

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានទោសរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សំដីចុងក្រោយបង្អស់របស់ជនជាប់ចោទ

## តុលាការក្រុងព្រះសីហនុ

-ក្រោយពិបានពិនិត្យពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## យល់ឃើញថា

-តាមការអះអាងរបស់ឈ្មោះ **ឃ មរ** ថា ខ្លួនមិនបានធ្វើការវាយតប់ ឬ តប់កាំបិតទៅលើឈ្មោះ **ច គ** ដូចជនល្មើសថានោះឡើយ ។

-តាមការបញ្ជាក់របស់សាក្សីជុំវិញកន្លែងកើតហេតុ បានអោយដឹងថាកន្លងមកឈ្មោះ **៥** និង ឈ្មោះ **ន** បានឈ្លោះគ្នាម្តងរួចទៅហើយ ដោយសារឈ្មោះគ្មារវាងឈ្មោះ **៥** និងឈ្មោះ **ន** ឈ្មោះ **ច គ** ដែលជាបក្សពួករបស់ឈ្មោះ **ន** ក៏នាំគ្នាទៅរករឿងឈ្មោះ **៥** ដែលជាមិត្តភក្តិរបស់ឈ្មោះ **ឃ មរ** និង **ហ សន** ទៅដល់ផ្ទះ **ម ល** ក៏នាំគ្នារើសដុំថ្មគប់

សំដៅទៅផ្ទះ ម ឈ កំពុងតែហូបបាយពេលល្ងាច ជាហេតុធ្វើអោយ ម ឈ ដែលម្ចាស់ផ្ទះចេញមកសួរពេលនោះឈ្មោះ ច គ ស្មានតែ ម ឈ ថាឈ្មោះ ៥ ក៏ប្រើពាក្យសំដីថា "អា ៥ ហ្អែងចង់លេងជាមួយអញ" ក៏បក្ខពួកឈ្មោះ ច គ វាយទៅលើ ម ឈ តែម្តង ដោយប្រើខ្សែក្រវ៉ាត់ ចម្លើយសាក្សីអាចយកជាការបាន ។

-នៅពេលកើតហេតុដែលមានការឈ្លោះប្រកែកគ្នារវាងឈ្មោះ ង និង ឈ្មោះ ៥ នោះ គឺឈ្មោះ ឃ ឬ ជាអ្នកឃាត់ និង ចាប់កុំអោយឈ្លោះគ្នា តែត្រូវឪពុកឈ្មោះ ង ស្មានតែ ឃ ឬ វាយកូនគាត់ៗក៏វាយ ឃ ឬ មួយពិលទៅ នេះតាមចម្លើយសាក្សី និង ចម្លើយ ឃ ឬ ព្រមទាំងចម្លើយ ហ សន ឃើញថា មានការស៊ីសង្វាក់នឹងគ្នាអាចអោយតុលាការយកជាការបាន ។

-ឈ្មោះ ហ សន ជាជនជាប់ចោទដែរ គ្រាន់តែដើរជាមួយ ឃ ឬ និង មិត្តភក្តិខ្លួន ហើយមិនបានប្រព្រឹត្តអ្វីទាំងអស់ និង ឃើញកើតហេតុដូចសាក្សីនានាផងដែរ ។

-ការដែលឈ្មោះ ច គ ត្រូវរបួសក្បាលនោះ គឺដោយសារឈ្មោះ ៥, ឈ្មោះ ទ ៩ បានប្រើកាំបិតគប់ទៅលើ ច គ ផងដែរ ដែលជាមិត្តភក្តិរបស់ ឃ ឬ នោះ ។

-ក្រោយពេលប្រព្រឹត្តបទល្មើសឈ្មោះ ៥, ឈ្មោះ ទ ៩ បានរត់គេចខ្លួនរហូតដល់សព្វថ្ងៃ មិនដឹងថារស់នៅទីកន្លែងណាឡើយ ។

-តាមការស៊ើបអង្កេតរបស់នគរបាលបានឃើញថា អ្នកបង្ករបួសនោះ គឺឈ្មោះ ៥ និងឈ្មោះ ទ ៩ ហើយពុំមានប្រវត្តិរូបច្បាស់លាស់ទៀតផងដែរ ។

-ដោយសារការរត់គេចខ្លួនរបស់ជនដៃដល់ ហើយរកមិនឃើញជនរងគ្រោះ និង ដើមបណ្តឹងក៏ប្តឹងទៅលើឈ្មោះ ឃ ឬ និង ហ សន ដែលជាអ្នកនៅ និង ជាបក្ខពួករបស់ឈ្មោះ ៥ និង ទ ៩ ផងដែរ ការប្តឹង និង ការចោទប្រកាន់នេះ គឺមិនត្រឹមត្រូវឡើយ ។ អ្នកណាប្រព្រឹត្តអ្នកនោះត្រូវទទួលខុសត្រូវ និង អ្នកអត់ប្រព្រឹត្តបែរជាចោទប្រកាន់នេះ គឺជាការមិនត្រឹមត្រូវឡើយ ។

-តាមការឆ្លើយបញ្ជាក់របស់ឈ្មោះ ម ឈ ថាឈ្មោះ ឃ ឬ និងឈ្មោះ ហ សន មិនបានប្រព្រឹត្តអំពើបង្ករបួសទៅលើឈ្មោះ ច គ នោះឡើយ ព្រោះខ្លួនគាត់នៅកន្លែងកើតហេតុនេះរហូតចប់ ហើយខ្លួនគាត់ក៏ត្រូវរងរបួសដោយសារតែឈ្មោះ ឃ និងឈ្មោះ ច គ វាយដែរ ។ តែបែរជាមិនធ្វើការចោទប្រកាន់ឈ្មោះ ច គ និង ឃ ទៀតផង ។

-តាមចម្លើយជនល្មើស និង សាក្សីបញ្ជាក់ថា ឈ្មោះ ឃ ឬ និងឈ្មោះ ហ សន មិនបានប្រព្រឹត្តបង្ករបួសដោយចេតនានោះឡើយ ។

-គ្មានពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ ឃ ឬ និង ឈ្មោះ ហ សន ពីបទបង្ករបួសដោយចេតនា ប្រព្រឹត្តនៅសង្កាត់វាលរេញ ខណ្ឌព្រៃនប់ ក្រុងព្រះសីហនុ កាលពីថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ២០០៣ ។

## ហេតុដូច្នេះតុលាការខេត្តព្រះសីហនុ

## សំរេច :

ផ្តន្ទាទោស :

១-ឈ្មោះ ឃ ឬ និង ឈ្មោះ ហ សន រួចផុតពីបទចោទប្រកាន់របស់តំណាងអយ្យការ តាមដីកាសន្និដ្ឋានស្ថាពរលេខ ៤៤៥ ដសព.04 ចុះថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ២០០៤ គិតពីថ្ងៃនេះតទៅ ។

២-អោយឈ្មោះ ឃ ឬ និងឈ្មោះ ហ សន មានសិទ្ធិសេរីភាពឡើងវិញ ដូចពលរដ្ឋធម្មតា គិតចាប់តាំងពីថ្ងៃនេះតទៅ ។

សាលក្រមនេះជំនុំជំរះ និង ប្រកាសជាសាធារណៈនៅចំពោះមុខជនជាប់ចោទ កំបាំងមុខជនរងគ្រោះ ដើមបណ្តឹង បើកផ្លូវប្តឹងទាស់ និង ប្តឹងឧទ្ធរណ៍ក្នុងកំឡុងច្បាប់ ។

ក្រឡាបញ្ជី
[redacted]

ចៅក្រមជំនុំជំរះ
[redacted]